CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៦ ខែកក្កដាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចបានប្រកាសផ្លាស់ប្តូរទីតាំងធ្វើតេស្តិ៍និងម៉ោងដើម្បីបង្កើនសមត្ថភាពក្នុងការធ្វើតេស្តិ៍ COVID-១៩

*ទីក្រុងឡុងប៊ិចឥឡូវមានសមត្ថភាពអាចធ្វើតេស្តិ៍ច្រើនជាង ១៤០០ អ្នកក្នុងមួយថ្ងៃ*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងឡុងប៊ិចបានធ្វើការផ្លាស់ប្តូរម៉ោងធ្វើការនៅទីតាំងធ្វើតេស្តិ៍ COVID-១៩ ដែលបានចូលជាធរមាននៅថ្ងៃទី ១៥ ខែកក្កដា។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ការធ្វើតេស្តិ៍មានសារសំខាន់ក្នុងការការពារការរីករាលដាលនៃជំងឺ COVID-១៩។ ក្នុងពេលនេះឡុងប៊ិចនៅតែបន្តផ្តល់ការធ្វើតេស្តិ៍ដោយឥតគិតថ្លៃដល់អ្នករស់នៅក្នុងក្រុងហើយបានស្នើឱ្យមនុស្សគ្រប់រូបធ្វើផ្នែករបស់ខ្លួនដើម្បីរក្សាខ្លួនគ្រួសាររបស់ខ្លួនសហគមន៍និងជាពិសេសបុគ្គលិកសុខាភិបាលរបស់យើងឲ្យមានសុវត្ថិភាព។"

ម៉ោងថ្មីសម្រាប់ការធ្វើតេស្តិ៍នឹងជួយឱ្យទីក្រុងនេះមានសមត្ថភាពធ្វើតេស្តិ៍ច្រើនជាង ១៤០០ អ្នកក្នុងមួយថ្ងៃ (ដែលជាចំនួនកើនឡើងពីចំនួនតេស្តិ៍ ១.០០០ កាលពីមុន)។ ទីក្រុងឡុងប៊ិចអាចឆ្លងដល់សមត្ថភាពនេះបានដោយការរួមដៃជាមួយទីតាំងដែលគ្រប់គ្រងដោយរដ្ឋនៅសាលារៀន Jordan Plus High School។ នេះជាសមត្ថភាពធ្វើតេស្តិ៍ខ្លាំងបំផុតដែលទីក្រុងមិនធ្លាប់មានពីមុននិងជាចំនួនជិតទ្វេដងនៃតំរូវការរបស់រដ្ឋ។

កន្លែងធ្វើតេស្តិ៍ដែលដំណើរការដោយក្រុងគឺមានដូចខាងក្រោម៖

- មហាវិទ្យាល័យនៃទីក្រុងឡុងប៊ិច (LBCC), សាខាឆ្នេរសមុទ្រប៉ាស៊ីហ្វិក (ដែលមានទីតាំងនៅអាសយដ្ឋាន 1305 E. Pacific Coast Hwy.) ដែលបើកចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ១ រសៀលពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។
- មហាវិទ្យាល័យនៃទីក្រុងឡុងប៊ិច (LBCC), នៅឯស្តាត Veterans Memorial (ដែលមានទីតាំងនៅអាសយដ្ឋាន 5000 E. Lew Davis St.) ដែលបើកចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ១ រសៀលនិងចាប់ពីម៉ោង ៣ រសៀលដល់ម៉ោង ៥ ល្ងាចពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។
- សាលារៀន Cabrillo High School (ដែលមានទីតាំងនៅអាសយដ្ឋាន 2001 Santa Fe Ave.) ដែលបើកចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ១ រសៀលនិងចាប់ពីម៉ោង ៣ រសៀលដល់ម៉ោង ៥ ល្ងាចនៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យ។

ម៉ោងធ្វើការនៅទីតាំងធ្វើតេស្តិ៍ខាងក្រោមគឺមិនមានការផ្លាស់ប្តូរទេ៖

- សាលារៀន Jordan Plus (ដែលមានទីតាំងនៅអាសយដ្ឋាន 171 W. Bort St.) ។ Jordan Plus High School (171 W. Bort St.) ផ្តល់ការធ្វើតេស្តិ៍សំរាប់បុគ្គលដែលមានរោគសញ្ញានិងអ្នកធ្វើការចាំបាច់ចាប់ពីម៉ោង ៧ ព្រឹកដល់ ៧ យប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។ សាលារៀន Jordan Plus មានផ្តល់ការធ្វើតេស្តិ៍ដោយមិនចាំបាច់មានយានយន្ត។ ប្រជាជនអាចដើរឡើងទៅដល់ទីតាំងដើម្បីទទួលការធ្វើតាស្ត៍បាន។

គ្លីនិកធ្វើរោគវិនិច្ឆ័យរហ័ស (RAC) ដែលមានទីតាំងនៅមហាវិទ្យាល័យទីក្រុងឡុងប៊ិច, សាខាឆ្នេរសមុទ្រប៉ាស៊ីហ្វិក (ដែលមានទីតាំងនៅអាសយដ្ឋាន 1305 E. Pacific Coast Hwy.) នឹងបន្តផ្តល់ការធ្វើតេស្តិ៍ដែលមិនផ្អែកលើយានយន្តនិងការថែទាំសុខភាពមួយចំនួនដល់បុគ្គលដែលមានរោគសញ្ញាចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ២ រសៀលពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។ អ្នកដែលមានរោគសញ្ញាដែលមិនអាចរកការធ្វើតេស្តិ៍បាននៅកន្លែងផ្សេងអាចទៅទីតាំងនេះដើម្បីទទួលការវាយតម្លៃផ្អែកសុខភាពដោយឥតគិតថ្លៃ។ ចំពោះបុគ្គលដែលមានរោគសញ្ញាគ្លីនិកវាយតម្លៃរហ័សគឺជាទីតាំងតែមួយគត់ដែលអាចផ្តល់ការណាត់ជួបនិងសេវាកម្មភ្លាមៗនៅនឹងកន្លែង។ កន្លែងធ្វើតេស្តិ៍ផ្សេងទៀតគឺតម្រូវឲ្យមានការណាត់ជួបជាមុន។

ទីតាំងនៅឯសាលារៀន Jordan High School បានបិទហើយប៉ុន្តែសមត្ថភាពក្នុងការធ្វើតេស្តិ៍ក្នុងក្រុងនៅតែដដែលពីពោះចំនួនតេស្តិ៍ដែលធ្លាប់ផ្តល់ជូននៅទីតាំងនេះត្រូវបានបង្វែរទៅទីតាំងផ្សេងទៀតនៅក្នុងក្រុងដែលកំពុងបើក។

សេវាកម្មធ្វើតេស្តិ៍បែបចល័តតាមផ្ទះក៏នៅតែបន្តផ្តល់ជូនដល់អ្នកដែលមិនអាចចេញពីផ្ទះបានដោយសារតែបញ្ហាផ្សេងៗទាក់ទងនឹងការធ្វើដំណើរឬបញ្ហាសុខភាពរ៉ាំរ៉ៃ។ ការធ្វើតេស្តិ៍ចល័តតាមផ្ទះអាចធ្វើបាននៅឯគេហដ្ឋានឬនៅកន្លែងនានាដូចជាផ្ទះស្តារនីតិសម្បទា កន្លែងថែទាំជំនាញ និងកន្លែងរស់នៅបែបសហគមន៍រួមផ្សេងៗ។ ដើម្បីស្នើសុំការធ្វើតេស្តិ៍បែបចល័តតាមផ្ទះសូមបំពេញទម្រង់បែបបទដែលមាននៅ[ទីនេះ]ឬទូរស័ព្ទមកខ្សែព័ត៌មានសុខភាពសាធារណៈតាមលេខ (562) 570-4636 (ចាប់ពីម៉ោង ៨ ព្រឹកដល់ ៥ ល្ងាច)។ ការធ្វើតេស្តិ៍បែបចល័តតាមផ្ទះគឺមានពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។

ការណាត់ជួបអាចកំណត់តាម[អ៊ិនធរណេត]ឬដោយទូរស័ព្ទមកលេខ 562.570.INFO (4636)។ ការធ្វើតេស្តិ៍ដោយឥតគិតថ្លៃនឹងផ្តល់ជូនដល់ពលរដ្ឋទាំងអស់នៃទីក្រុងឡុងប៊ិច ទីក្រុង Signal Hill ទីក្រុង Lakewood ទីក្រុង Paramount និងទីក្រុង Compton។ ពេលវេលាណាត់ជួបនឹងមានផ្តល់ជូនរហូតដល់ទៅបីថ្ងៃជាមុន។

ទីក្រុងនៅតែប្តេជ្ញាធ្វើឲ្យការធ្វើតេស្តិ៍តមានសម្រាប់អ្នករស់នៅទីក្រុងឡុងប៊ិចទាំងហស់។ រហូតមកដល់ពេលនេះឡុងប៊ិចបានអនុវត្តតេស្តិ៍ COVID-១៩ ជាង 103,000 តេស្តិ៍តាមរយៈទីតាំងដែលគ្រប់គ្រងដោយទីក្រុង កន្លែងដែលគ្រប់គ្រងដោយរដ្ឋ និងមន្ទីរពិសោធន៍ឯកជន។ បន្ថែមពីលើជម្រើសធ្វើតេស្តិ៍សាធារណៈទាំងនេះបុគ្គលម្នាក់ៗអាចទទួលបានការធ្វើតេស្តិ៍ COVID-១៩ តាមរយៈគ្រូពេទ្យរបស់ពួកគាត់។ ឥឡូវនេះនៅឡុងប៊ិចករណីជំងឺ COVID-១៩ គឺមានចំនួន ៦.២៥២ អ្នកហើយមនុស្ស ១៥៧ អ្នកបានស្លាប់ដោយសារវីរុសនេះ។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-១៩ រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #